# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣១ អនក្រ.បក

## អនុក្រឹត្យ

ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស យូ ប៊ី អ៊ី ស្នួល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស យូ ប៊ី អ៊ី ស្នួល** ( U B E SNOUL SEZ ) ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងស្រែ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ។

**មាត្រា២.-**

តំបន់សេដ្ឋកិច្ចពិសេស យូ ប៊ី អ៊ី ស្នួល មានទំហំ ៨១៧.៨០ ហិកតា (ប្រាំបីរយដប់ប្រាំពីរហិកតា និងប៉ែតសិបអា) ដូចមានប្លង់ទីតាំង ព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ចជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស យូ ប៊ី អ៊ី ស្នួល** ដូចមានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស យូ ប៊ី អ៊ី ស្នួល** នេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តក្រចេះ និងក្រុមហ៊ុន យូ ប៊ី អ៊ី ឌីវេឡុបមេន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តាសោភា**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដី ខេត្តក្រចេះ

ប្លង់បង្ហាញទីតាំងក្បាលដី ដែលជាកម្មវត្ថុជួលរយៈពេលវែង
ជូនក្រុមហ៊ុន យូប៊ីអ៊ី ឌីវេឡុបមេន ខូអិលធីឌី សំរាប់បង្កើតតំបន់សេដ្ឋកិច្ចពិសេស
ដែលមានទីតាំងស្ថិតនៅ ភូមិក្រពាំងស្រែ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ

តារាងនិយាមកាព្រំដី

| Points_ID | Easting(m) | Northing(m) | Points_ID | Easting(m) | Northing(m) |
|---|---|---|---|---|---|
| 1 | 665415 | 1326247 | 24 | 662567 | 1323857 |
| 2 | 664192 | 1327876 | 25 | 662943 | 1324105 |
| 3 | 664114 | 1327794 | 26 | 662862 | 1324254 |
| 4 | 663960 | 1327834 | 27 | 662833 | 1324625 |
| 5 | 663954 | 1327802 | 28 | 662876 | 1324914 |
| 6 | 663766 | 1327819 | 29 | 663228 | 1324873 |
| 7 | 663823 | 1328019 | 30 | 663216 | 1324793 |
| 8 | 663472 | 1327769 | 31 | 663218 | 1324582 |
| 9 | 663446 | 1327815 | 32 | 663380 | 1324569 |
| 10 | 661440 | 1326319 | 33 | 663391 | 1324494 |
| 11 | 661757 | 1326315 | 34 | 663410 | 1324474 |
| 12 | 661110 | 1325830 | 35 | 663500 | 1324536 |
| 13 | 661657 | 1325080 | 36 | 663600 | 1324651 |
| 14 | 662021 | 1325384 | 37 | 663599 | 1324676 |
| 15 | 662303 | 1324874 | 38 | 663570 | 1324762 |
| 16 | 662352 | 1324912 | 39 | 663600 | 1324836 |
| 17 | 662503 | 1324702 | 40 | 663708 | 1324946 |
| 18 | 662457 | 1324579 | 41 | 664177 | 1325249 |
| 19 | 662432 | 1324501 | 42 | 664210 | 1325299 |
| 20 | 662378 | 1324451 | 43 | 664261 | 1325386 |
| 21 | 662243 | 1324446 | 44 | 664435 | 1325476 |
| 22 | 662225 | 1324396 | 45 | 665163 | 1326028 |
| 23 | 662205 | 1324371 | 46 | 665145 | 1326058 |




សញ្ញាសំគាល់

ផ្លូវជាតិលេខ ៧៤

បង្គោលព្រំដី

A ក្បាលដីតំបន់សេដ្ឋកិច្ចពិសេសទំហំ= ៨១៧.៨០ ហិកតា

មាត្រដ្ឋាន: 1:18,000

វាស់វែង និងគូសដោយមន្ត្រីការិយាល័យ សុរិយោដី និងភូមិសាស្ត្រ
ឧបករណ៍វាស់វែង: GPS Leica Viva Uno

វាស់វែង និងគូសដោយ
ថ្ងៃទី១២..ខែមិថុនា..ឆ្នាំ២០១៦
ហត្ថលេខា
សិរិន សុវណ្ណមុនី

បានឃើញ និងពិនិត្យត្រឹមត្រូវ
គោរពជូន
លោកប្រធានមន្ទីរ មេត្តាពិនិត្យ និងសម្រេច
ក្រចេះ. ថ្ងៃទី១២..ខែមិថុនា..ឆ្នាំ២០១៦
ប្រធានការិយាល័យសុរិយោដី និងភូមិសាស្ត្រ

ឌី សុវណ្ណារ៉ា

លេខ:..៣៣០ទី..ន.ន.សក.ក្រច
បានឃើញ និងឯកភាព
ក្រចេះ. ថ្ងៃទី១៤..ខែ..មិថុនា....ឆ្នាំ២០១៦
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដីខេត្តក្រចេះ

បណ្ឌិត.ចៅ..ម៉ាឌីឡេន